22. បិតាអើយ
សូមផ្តល់ឱ្យស្ត្រីនៅក្នុងប្រទេសប្រេស៊ីលទទួលបានការអប់រំ និងឱកាសការងារដែលល្អ។
សូមអោយពួកគេបានមានភាពជិតស្និតជាមួយទ្រង់ និងប្រទានកម្លាំងដល់ពួកគេក្នុងការដែលគេមើលថែរក្រុមគ្រួសាររបស់ពួកគេផងដែរ។
(ទំនុកតម្កើង ១៤៥:១៥)

23. ឱ ព្រះអម្ចាស់អើយ
ស្ត្រីជាច្រើននៅក្នុងប្រទេសហុងឌូរ៉ាសបានទទួលរងនូវការឈឺចាប់នៅពេលដែលពួកគេឃើញកូនរបស់ពួកគេពាក់ព័ន្ធនឹងក្រុមក្មេងទំនើង។ សូមរំដោះយុវជនទាំងនេះឲ្យរួចផុតពី
ការល្បួងលដែលនាំអោយពួកគេដើរខុសក្នុងជីវិតនេះផងដែរ។ (២កូរិនថូស ៥:១៧)

24. ព្រះអម្ចាស់ អើយ
សូមប្រទានបំណងចិត្តដែលចង់ថ្វាយសិរីល្អដល់ព្រះនាមទ្រង់ទៅដល់ក្រុមអ្នកដឹកនាំប្រចាំតំបន់នៅសហរដ្ឋអាមេរិក
ហើយអោយពួកគេពឹងផ្អែកលើទ្រង់ក្នុងគ្រប់កិច្ចការដែលពួកគេធ្វើ។ (អេសាយ ៤១:១៣)

25. ព្រះវរបិតា អើយ សូមបើកទ្វារ
និងផ្តល់ធនធានគ្រប់គ្រាន់ដល់ព័ន្ធកិច្ចស្ត្រីក្នុងក្តីសង្ឃឹម របស់TWR នៅប្រទេសប៉ារ៉ាហ្គាយ
ដើម្បីអោយពួកគេបានឈោងចាប់ស្ត្រីនៅក្នុងពន្ធនាគានៅទីនោះ
ជាមួយនឹងព្រះបន្ទូលនៃសេចក្តីសង្គ្រោះដែលមាននៅក្នុងព្រះយេស៊ូវគ្រីស្ទផងដែរ។ (១កូរិនថូស ១៥:៥៨)

26. ព្រះជាម្ចាស់អើយ
យើងអធិស្ឋានសុំឱ្យស្ត្រីជនជាតិអ៊ុយរូហ្គាយទាំងអស់បានរកឃើញទ្រង់ហើយដឹងថាពួកគេមានតម្លៃសម្រាប់ទ្រង់ និងរៀនឱ្យតម្លៃទៅខ្លួនឯងផងដែរ។
(អេសាយ ៦២:៣)

27. ព្រះបិតា អើយ
យើងសូមអរព្រះគុណចំពោះឱកាសជាច្រើនដែលទ្រង់បានប្រទានមកដល់កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹមនៅប្រទេស Brazil ដើម្បីធ្វើកិច្ចប្រជុំមួយ
និងព្រឹត្តិការណ៍ដែលនិយាយអំពីស្ត្រីផងដែរ។
សូមឱ្យស្ត្រីទាំងអស់ត្រូវបានពង្រឹងនិងរីកចម្រើនក្នុងសេចក្តីស្រឡាញ់របស់ពួកគេចំពោះទ្រង់ថែមទៀត។
(អេភេសូរ ១:១៧)

28. ព្រះអម្ចាស់អើយ
សូមប្រទានពរដល់ក្រុមការងារនៅប៉ារ៉ាហ្គាយ
ដែលធ្វើការជាមួយអ្នកស្ម័គ្រចិត្ត
និងក្រុមមូលនិធិដើម្បីអោយប្រតិទិននៃសេចក្តីអធិស្ឋានអាចត្រូវបានបកប្រែ និង
ផលិតជាភាសាហ្គារ៉ានីនៅឆ្នាំនេះផងដែរ។
(ទំនុកដំកើង ១១២:៥)

29. ព្រះអម្ចាស់អើយ
យើងសូមឱ្យស្ត្រីជនជាតិប៉េរូបានលឺពីសារនៃដំណឹងល្អរបស់ទ្រង់។ (រ៉ូម ១០:១៧)

30. យើងសូមសរសើរតម្កើងទ្រង់ បិតាអើយ
ដែលក្រុមអ៊ុយរូហ្គាយរបស់យើងអាចផ្ញើប្រតិទិនអធិស្ឋានតាមរយៈបណ្តាញសង្គម
ហើយជួបជុំគ្នាដើម្បីអធិស្ឋានតាមអ៊ិនធឺណិតបាននាពេលបច្ចុប្បន្ននេះ។ (ទំនុកដំកើង ១១៨:១)

31. ព្រះអម្ចាស់អើយ សូមនាំមកនូវការព្យាបាល និងការស្តារឡើងវិញដល់ស្ត្រីដែលរស់នៅសាធារណរដ្ឋដូមីនិក
ដែលជាជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារផងដែរ។ (អេសាយ ៣៣:២)

후원안내

국민은행 851-01-0003-724 북방선교방송

최초 입금 후 사무실로 연락 주시기 바랍니다

# Women of Hope

## Prayer Calendar

ប្រតិទិនអធិស្ឋានចេញផ្សាយជារៀងរាល់ខែ ដែលមានជាង
100ភាសា និងមានអ្នកចូលរួមអធិស្ឋានជាង 65,000នាក់



**2023. 1.**
**ការអធិស្ឋានសម្រាប់ស្ត្រីនៅអាមេរិកខាងជើងនិងខាងត្បូង**

ថ្ងៃថ្មីបានរះឡើង ឯឆ្នាំថ្មីក៏បានចាប់ផ្តើមផងដែរ។
តើអ្នកមានគោលដៅអ្វីសម្រាប់ឆ្នាំនេះឬទេ?
តើអ្នកបានរំពឹងទុកអោយមានការផ្លាស់ប្តូរអ្វីខ្លះក្នុងជីវិតរបស់អ្នកក្នុងឆ្នាំនេះ?
ជាមួយនឹងការផ្លាស់ប្តូរនឹងនាំមកនូវការរីកចម្រើន,
ជាមួយនឹងការរីកចម្រើននឹងនាំមកនូវការផ្លាស់ប្តូរ
ខ្ញុំសង្ឃឹមថាអ្នកកាន់តែរីកចម្រើនក្នុងការអធិស្ឋាន
ជាពិសេសការអធិស្ឋានសម្រាប់អ្នកដទៃ។
វានឹងផ្លាស់ប្តូរជីវិតរបស់អ្នក។វានឹងបង្កើនសេចក្តីស្រឡាញ់របស់យើងចំពោះអ្នកដទៃទៀតផងដែរ។

**TWR Korea 북방선교방송**

서울특별시 관악구 양녕로 15, 월드빌딩 6층

전화 (02)886-5671 / 이메일 phkorea@twrk.or.kr

**អធិស្ឋានសំរាប់...............**

1. ព្រះអង្គអើយ
សូមឲ្យស្ត្រីជនជាតិអ៊ុយរូហ្គាយចេះឲ្យតម្លៃលើខ្លួនឯង
និងមិនអនុញ្ញាតឱ្យអ្នកដទៃប្រើប្រាស់ពួកគេដូចជាវត្ថុក្នុ
ងការសប្បាយមួយគ្រាជាថ្នូរប្តូរនឹងប្រាក់នោះឡើយ។
(ទំនុកដំកើង ៣៤:៥)

2. ឱ ព្រះជាម្ចាស់អើយ
យើងខ្ញុំសូមសរសើរតម្កើងព្រះអង្គសម្រាប់ការចែករំលែក
ទីបន្ទាល់របស់ប្រជាជននៃប្រទេស Bonaire
នៅលើគេហទំព័រ Facebook
តាមរយៈកម្មវិធីស្ត្រីក្នុងក្តីសង្ឃឹមរបស់យើង។
សូមឱ្យទីបន្ទាល់របស់ពួកគេបានជាទីផ្តល់ក្តីសង្ឃឹមដល់អ្ន
កដទៃផងដែរ។ (ទំនុកដំកើង ៦៦:១៦)

3. បិតាអើយ សូមឲ្យសារក៏ដូចជាមេរៀនស្ត្រីនៃក្តីសង្ឃឹម
ដែលបានចាក់ក្នុងប្រព័ន្ធផ្សព្វផ្សាយ
នៅប្រទេសកាណាដាទៅកាន់ប្រទេសនានាជុំវិញពិភព
លោក សូមនាំមកនូវសន្តិភាព ការព្យាបាល
និងផ្សះផ្សារទំនាក់ទំនងអ្នកស្តាប់ជាមួយទ្រង់ផងដែរ ។
(អេសាយ ៥៥:១០-១១)

4. ព្រះអម្ចាស់អើយ សូមប្រើប្រាស់ឆានែល YouTube
របស់យើងដែលមានវីដេអូថ្វាយបង្គំប្រចាំសប្តាហ៍ជាភា
សាកាយវិការដើម្បីទាក់ទាញស្ត្រីជាច្រើននៅក្នុងប្រទេស
ប្រេស៊ីល អោយមករកទ្រង់
និងជួយពួកគេឱ្យរីកចម្រើនក្នុងសេចក្តីជំនឿរបស់ពួក
គេផងដែរ។ (២ពេត្រុស ៣:១៨)

5. ព្រះជាអម្ចាស់អើយ
សូមទ្រង់សម្រេចនូវបំណងចិត្តរបស់ក្រុមប៉ារ៉ាហ្គាយរបស់
យើងក្នុងការពង្រីកការចាក់ផ្សាយវិទ្យុនៅក្នុងផ្នែកមួយ
នៅខាងក្នុងនៃប្រទេសតាមរយៈកម្មវិធីរបស់យើងជាភា
សាអេស្ប៉ាញ អាល្លឺម៉ង់ និងហ្គារ៉ានី។ (អេសាយ ៥៤:២)

6. បិតាអើយ សូមនាំអ្នកស្ម័គ្រចិត្តដែលស្រលាញ់ទ្រង់
និងឈោងចាប់ដល់អ្នកដទៃដើម្បីជួយក្រុមការងារប្រចាំ
តំបន់នៅសហរដ្ឋអាមេរិកជាមួយនឹងការងារដែលទ្រង់
បានផ្តល់ឱ្យពួកគេ។ (១យ៉ូហាន ៣:១៨ )

7. ព្រះអម្ចាស់អើយ
យើងខ្ញុំអធិស្ឋានសុំអោយសេចក្តីមេត្តាករុណារបស់ទ្រង់
បានមានចំពោះស្ត្រីនៅប្រទេសហុងឌូរ៉ាស
ដែលទទួលរងនូវអំពើហិង្សាក្នុងគ្រួសារ។
សូមផ្តល់វិធីសាស្ត្រដើម្បីអោយពួកគេចាកចេញពីទុក្ខលំ
បាកនេះផងដែរ។ (អេសាយ ២៥:៤)

8. ឱព្រះវរបិតាអើយ
ទូលបង្គំអធិស្ឋានឲ្យអ្នកទោសស្ត្រីនៅសាធារណរដ្ឋដូមីនី
កែន ឮសារដំណឹងល្អ ផ្សះផ្សាជាមួយនឹងទ្រង់
ហើយស្វែងរកសេរីភាពរបស់ពួកគេក្នុងទំនាក់ទំនងរបស់
ពួកគេជាមួយទ្រង់។ (កិច្ចការ ៣:១៩)

9.ព្រះអម្ចាស់អើយសូមនាំសន្តិភាពដល់ស្ត្រីនៅប្រទេសហុ
ងឌូរ៉ាសដែលត្រូវបានទុកចោលតែម្នាក់ឯងនៅពេលដែ
លកូនៗ និង
ប្តីរបស់ពួកគេធ្វើចំណាកស្រុកទៅកាន់ប្រទេសផ្សេងទៀត
ដើម្បីរួចផុតពីភាពក្រីក្រនិងឧក្រិដ្ឋកម្មនៅក្នុងប្រទេសកំ
ណើតរបស់ពួកគេ។ (ភីលីព ៤:៦)

**Phum Roung Chak, Sangkat Kok Kleang,**

**Khan Sen Sok, Phnom Penh**

**(ភូមិរោងចក្រ សង្កាត់គោកឃ្លាង ខ័ណ្ឌសែនសុខរាជធានីភ្នំពេញ )**

**Tel: 092 60 60 51 /086 60 60 56**

10. ព្រះជាម្ចាស់
យើងសរសើរតម្កើងទ្រង់ដែលបានអោយបុរសនិងស្ត្រីនៃ
ប្រទេស Bonaire
កាន់តែមានទំនាក់ទំនងកាន់តែស៊ីជម្រៅជាមួយទ្រង់
តាមរយៈព័ន្ធកិច្ចស្ត្រីក្នុងក្តីសង្ឃឹមTWR ។ (សុភាសិត
៣:៥-៦)

11. បិតាអើយ
សូមផ្តល់បណ្តាញដ៏រឹងមាំសម្រាប់ស្ត្រីមេម៉ាយនៅប្រទេស
ប្រេស៊ីលដែលត្រូវការធ្វើការ
និងមើលថែគ្រួសាររបស់ពួកគេ។ (កាឡាទី ៦:២)

12. ឱព្រះវរបិតាអើយ
យើងសូមសរសើរតម្កើងទ្រង់ចំពោះការឆ្លើយការអធិស្ឋា
ន
និងអនុញ្ញាតឱ្យក្រុមប៉ារ៉ាហ្គាយនាំយកព្រះបន្ទូលរបស់ទ្រ
ង់ទៅកាន់យុវនារីនៅឯមណ្ឌលកែប្រែអនីតិជន។
(កាឡាទី ៦:៩)

13. បិតាអើយ
សូមផ្តល់ឱ្យក្រុមការងារនៅក្នុងប្រទេសកាណាដានូវលទ្ធ
ភាពក្នុងការមើលឃើញ និង
អនុវត្តន៍នូវឱកាសថ្មីៗដែលទ្រង់បានផ្តល់ឱ្យពួកគេ
ក្នុងការទាក់ទងទៅកាន់ស្ត្រីនៅក្នុងប្រទេសរបស់ពួកគេ
ផងដែរ។ (១ពេត្រុស ៤:១០)

14. ព្រះអង្គអើយ
យើងអធិស្ឋានសម្រាប់ក្មេងស្រីជំទង់នៅអ៊ុយរូហ្គាយដែល
មានគំនិតចង់ធ្វើអត្តឃាត។សូមឱ្យពួកគេបានរកឃើញ
ទ្រង់ និង មានហេតុផលដើម្បីរស់នៅបន្តទៀត។
(ទំនុកតម្កើង ៤២:១១)

15. ឱ ព្រះអម្ចាស់អើយ
សូមប្រទានប្រាជ្ញាដល់អ្នកដឹកនាំតាមតំបន់នានាទូទាំង
ពិភពលោករបស់TWR
យើងនៅពេលពួកគេចាប់ផ្តើមរៀបចំផែនការអភិវឌ្ឍ
និងផលិតកម្មវិធីដែលមានឈ្មោះថា Precious and
Belovedដែលជាកម្មវិធីថ្មីរបស់កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹមរប
ស់យើង។ (សុភាសិត ២:៦)

16.បិតាអើយ សូមមើលថែស្ត្រីដែលមានភាពចាស់ទុំ និង
គោរពកោតខ្លាចព្រះនៅក្នុងប្រទេសប្រេស៊ីល
ដើម្បីអោយពួកគេបានលើកទឹកចិត្តស្ត្រីផ្សេងទៀតក្នុង
ការដើរជាមួយទ្រង់ផងដែរ។ (ម៉ាថាយ ២៨:១៩-២០)

17. ឱ ព្រះវរបិតាអើយ
សូមអោយស្ត្រីវ័យក្មេងនៅប្រទេសកូឡុំប៊ី
ដែលកំពុងជួបប្រទះវិបត្តិនៃការបាត់បង់អត្តសញ្ញាណ
សូមឱបក្រសោបនិងកែច្នៃពួកគេអោយនៅជាប់ជាមួយ
ព្រះហឫទ័យរបស់ទ្រង់ផងដែរ។ (១យ៉ូហាន ៣:១)

18. ព្រះវរបិតាអើយ ប្រជាជននៃប្រទេស Bonaire
ដឹងថាអ្នកដឹកនាំដែលល្អគឺមកពីទ្រង់។ សូមផ្តល់ការយល់
ដឹងដល់ពួកគេដើម្បីធ្វើការសម្រេចចិត្តក្នុងការបោះ
ឆ្នោតប្រកបដោយប្រាជ្ញាផងដែរ។ (ម៉ាថាយ ២០:២៦)

19. ព្រះដ៏ជាអម្ចាស់អើយ យើងសូមសរសើរតម្កើងទ្រង់
ដែលពេលនេះក្រុមការងារនៅ Paraguay
បានធ្វើការចែកចាយព្រះបន្ទូលរបស់ទ្រង់
តាមរយៈវីដេអូខ្លីមួយនាទីជាភាសា Guarani
នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។ (ម៉ាថាយ ៤:៤)

20. បិតា អើយ
សូមអោយស្ត្រីប៉ាណាម៉ាដែលមិនត្រូវបានធ្លាក់ចូលក្នុងកា
រល្បួងលអោយមានការជួញដូរផ្លូវភេទ
បានទទួលការងារនៅក្រៅប្រទេសដែលមានប្រាក់ខែសម
រម្យក្នុងការចិញ្ចឹមជីវិតផងដែរ។ (សុភាសិត ១៩:២០)

21. ឱព្រះវរបិតា អើយ សូមការពារ និងព្យាបាលស្ត្រី
និងកុមារនៅអ៊ុយរូហ្គាយដែលជួបប្រទះនូវអំពើហិង្សាក្នុង
គ្រួសារ និងផ្លាស់ប្រែចិត្តអ្នកដែលធ្វើបាបពួកគេផងដែរ។

(ទំនុកតម្កើង ២៨:៦)